ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៤៣៦ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ចំណាត់ថ្នាក់នៃអនុលោមភាពសារពើពន្ធ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ១.. គោលបំណង**

ប្រកាសនេះ មានគោលបំណងកំណត់នូវលក្ខណៈវិនិច្ឆ័យដើម្បីធ្វើចំណាត់ថ្នាក់អនុលោមភាពសារពើពន្ធរបស់អ្នកជាប់ពន្ធ។

**ប្រការ២.. គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់នូវចំណាត់ថ្នាក់អនុលោមភាពសារពើពន្ធរបស់អ្នកជាប់ពន្ធ ដើម្បីជំរុញការបំពេញកាតព្វកិច្ចសារពើពន្ធឱ្យកាន់តែប្រសើរឡើង។

**ប្រការ៣.. វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

**ប្រការ៤.. ការធ្វើចំណាត់ថ្នាក់អនុលោមភាពសារពើពន្ធរបស់អ្នកជាប់ពន្ធ**

ចំណាត់ថ្នាក់អនុលោមភាពសារពើពន្ធរបស់អ្នកជាប់ពន្ធ ត្រូវបានបែងចែកជា ៣ ប្រភេទគឺ មាស (អនុលោមភាពខ្ពស់) ប្រាក់ (អនុលោមភាពមធ្យម) និងសំរិទ្ធ (អនុលោមភាពទាប) ដោយផ្អែកលើពិន្ទុសរុបតាមលក្ខណៈវិនិច្ឆ័យដូចក្នុងតារាងខាងក្រោម÷

| ល.រ | លក្ខណៈវិនិច្ឆ័យ | ពិន្ទុ |
|---|---|---|
| ១ | បានចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពការចុះបញ្ជី | ១ |
| ២ | បានជូនដំណឹងអំពីការផ្លាស់ប្តូរព័ត៌មាននៃការចុះបញ្ជី | ១ |
| ៣ | បានដាក់លិខិតប្រកាសសារពើពន្ធទៀងទាត់តាមកាលកំណត់ | ១ |
| ៤ | បានបង់ប្រាក់ពន្ធដែលបានប្រកាសគ្រប់ចំនួនតាមកាលកំណត់ | ១ |
| ៥ | បានកាន់កាប់បញ្ជីកាគណនេយ្យ លិខិតយុត្តិការ និងឯកសារផ្សេងៗតាមការតម្រូវ | ២ |
| ៦ | បានចេញវិក្កយបត្រត្រឹមត្រូវលើរាល់ប្រតិបត្តិការតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ | ២ |
| ៧ | មិនបានប្រព្រឹត្តអំពើធ្វេសប្រហែសដូចមានចែងក្នុងមាត្រា១២៥នៃ ច.ស.ព | ២ |
| ៨ | មិនបានប្រព្រឹត្តអំពើធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា១២៦នៃ ច.ស.ព | ២ |
| ៩ | បានបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗដែលរដ្ឋបាលសារពើពន្ធបានកំណត់ | ២ |
| ១០ | មិនបានកសាង ឬផ្តល់កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំផ្សេងៗ | ២ |
| ១១ | បានផ្តល់កិច្ចសហការនិងអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធពិនិត្យបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ | ២ |
| ១២ | មិនត្រូវបានរកឃើញថាបានអនុវត្តការផ្ទេរថ្លៃរវាងបុគ្គលទាក់ទិន | ២ |
| សរុប | | ២០ |

អ្នកជាប់ពន្ធត្រូវបានចាត់ទុកថាមានលក្ខណៈសម្បត្តិជាប្រភេទ មាស ប្រាក់ ឬសំរិទ្ធ ដូចខាងក្រោម ÷

- ប្រភេទមាស សម្រាប់អ្នកជាប់ពន្ធដែលទទួលបានពិន្ទុសរុបចាប់ពី ១៦ ដល់ ២០

- ប្រភេទប្រាក់ សម្រាប់អ្នកជាប់ពន្ធដែលទទួលបានពិន្ទុសរុបចាប់ពី ១១ ដល់ ១៥
- ប្រភេទសំរិទ្ធ សម្រាប់អ្នកជាប់ពន្ធដែលទទួលបានពិន្ទុសរុបចាប់ពី ១ ដល់ ១០។

**ប្រការ៥.- វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ**

អគ្គនាយកដ្ឋានពន្ធដារ ត្រូវប្រគល់ជូនវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធចំពោះអ្នកជាប់ពន្ធប្រភេទមាស។ ដោយឡែក អ្នកជាប់ពន្ធប្រភេទប្រាក់ ឬសំរិទ្ធ អាចនឹងត្រូវប្រគល់ជូនវិញ្ញាបនបត្រអនុលោមភាពតាមការស្នើសុំ។

សុពលភាពនៃវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធមានរយៈពេល ២ ឆ្នាំ។ ក្នុងរយៈពេលនេះ អគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិដកហូតនិងវាយតម្លៃអនុលោមភាពសារពើពន្ធឡើងវិញ ក្នុងករណីដែលរកឃើញថា អ្នកជាប់ពន្ធមិនគោរពតាមលក្ខណៈវិនិច្ឆ័យដែលខ្លួនទទួលបាន។

អគ្គនាយកដ្ឋានពន្ធដារ ត្រូវរៀបចំគណៈកម្មការវាយតម្លៃកម្រិតអនុលោមភាពសារពើពន្ធរបស់អ្នកជាប់ពន្ធដោយមានការចូលរួមពីអង្គភាពពាក់ព័ន្ធនានា ដើម្បីធានានូវតម្លាភាពនៃកម្រិតអនុលោមភាពដែលមានផ្តល់ជូនអ្នកជាប់ពន្ធ។

**ប្រការ៦.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ